

ដោយ ប្រូគ្លីន ភី អាយុ ៩ ឆ្នាំ រដ្ឋយូថាហ៍ ស.រ.អា.

# តើខ្ញុំគួរតែបន្តអានទៀតឬ ?

ឆ្នាំមុន ខ្ញុំបានរើសសៀវភៅនៅបណ្ណាល័យដែលសរសេរអំពីក្មេងស្រីម្នាក់ចាប់ផ្ដើមសរសេរកំណត់ហេតុបណ្ដាញមួយ ។ ខ្ញុំបានគិតថា វាជាសៀវភៅដ៏រីករាយមួយ ដោយសារតួអង្គសំខាន់នោះគឺមានអាយុស្របាលនឹងខ្ញុំ ហើយម្ដាយខ្ញុំក៏ជាអ្នកសរសេរកំណត់ហេតុបណ្ដាញដែរ ។ ដូច្នេះខ្ញុំបានគិតថា វាជាសៀវភៅដែលខ្ញុំអាចអានបាន ។

ខ្ញុំបានអានតែពីរបីទំព័រប៉ុណ្ណោះ ពេលក្មេងស្រីនោះបានប្រើព្រះនាមរបស់ព្រះអម្ចាស់ជាអសារឥតការ ។ ខ្ញុំគ្មានអារម្មណ៍ល្អសោះ បន្ទាប់ពីខ្ញុំបានអានផ្នែកនោះ ។ ប៉ុន្តែខ្ញុំបានបន្តអានទៀត ដោយសង្ឃឹមថា វាគ្រាន់តែកើតឡើងតែម្ដងប៉ុណ្ណោះ ។ ខ្ញុំបានអានពីរបីទំព័របន្ថែមទៀត ហើយនាងនៅតែនិយាយពាក្យនោះដដែរ ។

ខ្ញុំបានប្រាប់ម្ដាយខ្ញុំអំពីអ្វីដែលខ្ញុំបានឃើញ ។ ខ្ញុំពុំដឹងថា តើខ្ញុំគួរបន្តអានសៀវភៅនោះទៀតឬក៏អត់ទេ ។ ម្ដាយខ្ញុំបានប្រាប់ខ្ញុំថា វាជាជម្រើសរបស់ខ្ញុំ ។ ប៉ុន្តែ គាត់បានយល់ស្របថា វាប្រហែលជាមិនមែនជារឿងល្អដើម្បីបន្តអានឡើយ ប្រសិនបើក្មេងស្រីនោះនិយាយពាក្យដែលយើងដឹងថា វាខុសនោះ ។ ម្ដាយខ្ញុំនិយាយថា ជាពិសេសវាអត់ល្អទេ ប្រសិនបើនាងបានប្រើព្រះនាមរបស់ព្រះអម្ចាស់ជាអសារឥតការនោះ ។

ខ្ញុំបានគិតថា ខ្ញុំនឹងមើលថា តើមានពាក្យនោះច្រើនដែរឬទេ ដូច្នេះខ្ញុំបានបើកមើលពេញសៀវភៅនោះ ។ ខ្ញុំបានឃើញថា ការយកព្រះនាមព្រះជាអសារឥតការ គឺជារបៀបដែលក្មេងស្រីនោះនិយាយជារឿយៗ ។ ខ្ញុំបានសម្រេចចិត្តយកសៀវភៅនោះទៅបណ្ណាល័យវិញ ដោយមិនបន្តអានវាទៀតទេ ។

ខ្ញុំសោកស្ដាយដែលអ្នកនិពន្ធសៀវភៅនេះបានប្រើព្រះនាមរបស់ព្រះអម្ចាស់ជាអសារឥតការ ។ បន្ទាប់ពីខ្ញុំបានយកសៀវភៅនោះទៅបណ្ណាល័យវិញ ខ្ញុំមានអារម្មណ៍រីករាយថា ខ្ញុំបានជ្រើសរើសធ្វើត្រឹមត្រូវ ។ ខ្ញុំដឹងថា ខ្ញុំកំពុងធ្វើតាម « បទដ្ឋានដំណឹងល្អរបស់ខ្ញុំ » ដកស្រង់មកពីសៀវភៅ *សេចក្ដីជំនឿលើព្រះ* ដែលចែងថា « ខ្ញុំនឹងអាន ហើយមើលតែអ្វីដែលគាប់ព្រះទ័យដល់ព្រះវរបិតាសួគ៌តែប៉ុណ្ណោះ » ។ ខ្ញុំដឹងថា យើងត្រូវប្រើព្រះនាមរបស់ព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទ ដោយគារវភាព និងគោរពជានិច្ច ។ ●



រចនារូបភាពដោយ ខនស្តាស្យា បាសាលូស្ស